មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

CCIM

cambodian center for independent media



# របាយការណ៍ស្តីពីការ តាមដានឧប្បត្តិហេតុយាយី ដល់អ្នកសារព័ត៌មាន

## ០៥

## កត់ត្រា ឧប្បត្តិហេតុ

**ករណីចាប់ខ្លួន**
(១ ករណី)

**ករណីរំខាន**
(១ករណី)

**ករណីគំរាមកំហែង**
(២ ករណី)

**ករណីយាយីតាមអ៊ីនធឺណិត**
(១ ករណី)

**របាយការណ៍ប្រចាំត្រីមាស ខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៥**

# របាយការណ៍ស្ដីពីការតាមដាន ឧប្បត្តិហេតុយាយីដល់អ្នកសារព័ត៌មាន

ចន្លោះពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៥ មជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (ស៊ីស៊ីអាយអឹម) បានបន្តការត្រួតពិនិត្យ និងកត់ត្រាករណីបំពាននានា ដែលមានគោលដៅលើអ្នកសារព័ត៌មាន និងបុគ្គលិកសារព័ត៌មាននៅកម្ពុជា។ ការកត់ត្រាករណីលើអ្នកសារព័ត៌មាន គឺជាឧបករណ៍សំខាន់មួយសម្រាប់តាមដាន និងឆ្លើយតបទៅនឹងការបំពាន និងការរំខានដែលបន្តកើតមានលើអ្នកសារព័ត៌មាន និងបុគ្គលិកសារព័ត៌មាន។

ករណីបំពានទាំងនេះ ដែលកើតមាននៅខេត្តនានានៅកម្ពុជា បង្ហាញពីបញ្ហាប្រឈមដែលអ្នកសារព័ត៌មាននៅតែជួបប្រទះ ក្នុងការរាយការណ៍អំពីបញ្ហាសាធារណៈ រួមមានការតវ៉ា សណ្តាប់ធ្នាប់សាធារណៈ និងបញ្ហាសន្តិសុខ។ ទោះបីជាកើតឡើងក្នុងបរិបទមូលដ្ឋានខុសៗគ្នាក៏ដោយ ករណីទាំងនេះ សរុបមកបង្ហាញពីលំនាំនៃការដាក់សម្ពាធ ការគំរាមកំហែង និងការដាក់កំហិត ដែលប៉ះពាល់ដល់សមត្ថភាពប្រពន្ធផ្សព្វផ្សាយក្នុងការបំពេញភារកិច្ចដោយសេរី និងឯករាជ្យ។




## ស៊ីស៊ីអាយអឹម បានកត់ត្រាករណីយាយីលើអ្នកសារព័ត៌មានចំនួន ០៥ ករណី

ករណីយាយីទាំងនេះបានប៉ះពាល់ដល់អ្នកសារព័ត៌មានអាជីព និងអ្នករាយការណ៍ព័ត៌មានពលរដ្ឋចំនួន១០នាក់ (ស្ត្រី ២នាក់)។ ករណីទាំងនេះរួមមាន ការចាប់ខ្លួនចំនួន ០១ ករណី ការគំរាមកំហែងចំនួន ០២ ករណី ការយាយីតាមអ៊ីនធឺណិតចំនួន ០១ ករណី និងការរំខានចំនួន ០១ ករណី។ ករណីបែបនេះឆ្លុះបញ្ចាំងពីការគម្រាមកំហែងជាបន្តបន្ទាប់ចំពោះសេរីភាពសារព័ត៌មាន និងគាបសង្កត់ធ្ងន់លើតម្រូវការបន្ទាន់សម្រាប់ការការពារកាន់តែរឹងមាំ និងបរិយាកាសដែលអ្នកសារព័ត៌មាន ទូទាំងប្រទេស អាចធ្វើការដោយសេរី និងសុវត្ថិភាពសម្រាប់អ្នកសារព័ត៌មានទូទាំងប្រទេស។

# របាយការណ៍ស្ដីពីការតាមដាន
# ឧប្បត្តិហេតុយាយីដល់អ្នកសារព័ត៌មាន

mCCIM
cambodian center for independent media

## ឧប្បត្តិហេតុសំខាន់ៗដែលកើតឡើងរួមមាន៖

១

**<u>ករណីទីមួយ</u>** ពាក់ព័ន្ធនឹងអ្នកសារព័ត៌មានអនឡាញម្នាក់មកពីសារព័ត៌មាន AK News ដែលកំពុងរាយការណ៍អំពីការតវ៉ា របស់ប្រជាពលរដ្ឋជុំវិញជម្លោះដីធ្លីនៅជិតផ្លូវជាតិលេខ៦A។ ក្នុងអំឡុងពេលព្យាយាមសម្ភាសន៍មន្ត្រីមូលដ្ឋាន ដើម្បីសួរអំពីដំណោះស្រាយជម្លោះ អ្នកសារព័ត៌មានរូបនេះ បានជួបប្រទះអាកប្បកិរិយាអវិជ្ជមានពីអភិបាលរងខេត្តកណ្ដាលម្នាក់។ ក្នុងវីដេអូដែលបានចែករំលែកលើបណ្ដាញសង្គមហ្វេសប៊ុក អភិបាលរងរូបនោះ ត្រូវបានឃើញថា<u>បានរុញអ្នកសារព័ត៌មាន និងប្រើពាក្យសម្ដីមិនសមរម្យ</u> នៅពេលអ្នកសារព័ត៌មានព្យាយាមសម្ភាសន៍។ អាកប្បកិរិយានេះ បានរំខានដល់ដំណើរការរាយការណ៍ព័ត៌មានអំពីការតវ៉ា និងបានកំណត់ការចូលដំណើរការព័ត៌មានផ្លូវការរបស់សាធារណជន ដែលបង្កើតបរិយាកាសនៃការភ័យខ្លាចមកលើអ្នកសារព័ត៌មាន និងការថយចុះនៃសេរីភាពសារព័ត៌មានឯករាជ្យនៅកម្រិតមូលដ្ឋានទៀតផង។

២

**<u>ករណីទីពីរ</u>** កើតឡើងលើអ្នកសារព័ត៌មានអនឡាញម្នាក់ទៀតមកពីអង្គភាពឌឹបដំណឹង បន្ទាប់ពីគាត់បានរាយការណ៍អំពីបញ្ហាអ្នកលក់ដូរតាមផ្លូវនៅជុំវិញផ្សារកំពតដែលបានផ្សព្វផ្សាយពីសណ្ដាប់ធ្នាប់សាធារណៈនៅក្នុងខេត្តនោះ។ ក្នុងវីដេអូមន្ត្រីនគរបាលមូលដ្ឋានជាច្រើន<u>បានព្យាយាមនាំអ្នកសារព័ត៌មានទៅកាន់ប៉ុស្តិ៍នគរបាល</u>ដើម្បីសួរនាំដោយមិនមានដីកាច្បាប់នោះឡើយ។ មន្ត្រីនគរបាលបានបញ្ជាក់ថាសកម្មភាពនេះធ្វើឡើងតាមសេចក្ដីបញ្ជាពីអភិបាលខេត្តខេត្តកំពត។ ទោះបីជាមិនមានការចោទប្រកាន់ផ្លូវការឡើយក៏ដោយ ការធ្វើបែបបទអនិរន្តរភាពនៃការអនុវត្តនេះ បានបង្កការព្រួយបារម្ភអំពីតម្លាភាព និងនីតិវិធីត្រឹមត្រូវ ក្នុងការទំនាក់ទំនងរវាងអាជ្ញាធរ និងអ្នកសារព័ត៌មាន។



# របាយការណ៍ស្ដីពីការតាមដានឧប្បត្តិហេតុយាយីដល់អ្នកសារព័ត៌មាន

## ឧប្បត្តិហេតុសំខាន់ៗដែលកើតឡើងរួមមាន៖

៣

**<u>ករណីទីបី</u>** ពាក់ព័ន្ធនឹងអ្នកសារព័ត៌មានស្ត្រីម្នាក់ ដែលបានប្រឈម និងពាក្យសម្ដីប្រមាថតាមបណ្ដាញសង្គមអ៊ីនធឺណិត បន្ទាប់ពីបានរាយការណ៍អំពីស្ថានការណ៍តានតឹងតាមព្រំដែនកម្ពុជា–ថៃ។ វីដេអូរបស់គាត់ ត្រូវបានចោទប្រកាន់ថាបង្ហាញទីតាំងជំរុំយោធាកម្ពុជា និងជំរុំជនភៀសខ្លួន ដែលត្រូវបានវាយប្រហារដោយកងទ័ពថៃ។ បន្ទាប់ពីការបង្ហោះព័ត៌មាន នាងត្រូវបានអ្នកប្រើប្រាស់បណ្ដាញសង្គមមួយចំនួន ចោទប្រកាន់ថាបានផ្សព្វផ្សាយព័ត៌មានរសើប និងព្យាយាមភ្ជាប់ការរាយការណ៍របស់គាត់ទៅនឹងការវាយប្រហារ។ <u>គាត់បានទទួលមតិយោបល់អវិជ្ជមានជាច្រើន និងត្រូវបានដាក់សម្ពាធឲ្យទទួលខុសត្រូវ ទោះបីជាព័ត៌មានដែលគាត់ប្រើប្រាស់ ផ្អែកលើប្រភពសាធារណៈ និងប្រភពផ្លូវការ រួមទាំងសេចក្ដីថ្លែងការណ៍ពីក្រសួងការពារជាតិក៏ដោយ</u>។ អ្នកសារព័ត៌មានរូបនេះ បានបដិសេធការចោទប្រកាន់ទាំងអស់ និងបញ្ជាក់ថាការងាររបស់គាត់ធ្វើឡើងដើម្បីផលប្រយោជន៍សាធារណៈ ហើយបានលើកឡើងពីតម្រូវការការពារអ្នកសារព័ត៌មាន ជាពិសេសស្ត្រី ពីការគំរាមកំហែង និងការរំខានផងដែរ។

៤

**<u>ករណីទីបួន</u>** ពាក់ព័ន្ធនឹងអ្នកសារព័ត៌មានអនឡាញម្នាក់មកពី CPN Newsនៅខេត្តបន្ទាយមានជ័យ ដែលត្រូវបានកងនគរបាលយោធាចាប់ឃុំខ្លួន ដោយចោទថាបានផ្ដល់ព័ត៌មានដោយខុសច្បាប់ដល់ជនបរទេស ក្នុងបរិបទជម្លោះតាមព្រំដែនកម្ពុជា–ថៃ។ អ្នកសារព័ត៌មានរូបនេះ ត្រូវបានឃុំខ្លួនតាំងពីពាក់កណ្ដាលខែធ្នូ ឆ្នាំ២០២៥ ហើយកំពុងរង់ចាំការជំនុំជម្រះផ្លូវការ។ ករណីនេះ បានបង្កការព្រួយបារម្ភយ៉ាងខ្លាំងដល់អ្នកសង្កេតការណ៍ ដោយសារការប្រើប្រាស់បរិបទសន្តិសុខជាតិ និងរយៈពេលឃុំខ្លួនដែលអូសបន្លាយ។



# របាយការណ៍ស្តីពីការតាមដាន ឧប្បត្តិហេតុយាយីដល់អ្នកសារព័ត៌មាន



## ឧប្បត្តិហេតុសំខាន់ៗដែលកើតឡើងរួមមាន៖

៥

**ករណីទីប្រាំ** ពាក់ព័ន្ធនឹងភាពតានតឹងតាមព្រំដែន ដោយអ្នកសារព័ត៌មានចំនួន ៦ នាក់ នៅក្នុងប្រទេសកម្ពុជា ត្រូវបាននគរបាល ឃុំ ដើងទៀន ខេត្តឧត្តរមានជ័យ សួរនាំជាបណ្ដោះអាសន្ន ខណៈពួកគេកំពុងកត់ត្រាស្ថានភាពនៅជិតកន្លែងផ្ទុះគ្រាប់បែក និងសម្ភាសន៍ប្រជាពលរដ្ឋដែលបានផ្លាស់ទីលំនៅនៅតំបន់នោះ។ នគរបាលបាននាំអ្នកសារព័ត៌មានទៅកាន់ប៉ុស្តិ៍នគរបាលឃុំ ដោយសង្ស័យអំពីសកម្មភាពចារកម្ម ដោយសារគ្មានលិខិតបេសកកម្មផ្លូវការ។ កាលពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២៥ ក្រសួងព័ត៌មាន បានចេញសេចក្ដីណែនាំ ដោយបញ្ជាក់ថា អ្នកសារព័ត៌មាន និងអ្នកប្រើប្រាស់បណ្ដាញសង្គម ត្រូវស្នើសុំលិខិតអនុញ្ញាត មុនចូលទៅតំបន់ជម្លោះ។ បន្ទាប់ពីពិនិត្យរូបថត និងសួរនាំអាជ្ញាធរ បានអនុញ្ញាតឱ្យអ្នកសារព័ត៌មានទាំង ៦ នាក់ ចាកចេញ និងបានស្នើឱ្យអ្នកសារព័ត៌មាន សហការ និងសម្របសម្រួលជាមួយអាជ្ញាធរ មុនចូលទៅតំបន់ដែលរងផលប៉ះពាល់ពីជម្លោះតាមព្រំដែន។




**ដើម្បីលើកកម្ពស់សុវត្ថិភាពអ្នកសារព័ត៌មាន ស៊ីស៊ីអាយអឹម នឹងបន្តត្រួតពិនិត្យ និងកត់ត្រាការរំលោភបំពានលើអ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងផ្ដល់ជំនួយផ្នែកច្បាប់ដល់អ្នកដែលប្រឈមនឹងហានិភ័យ។ ប្រសិនបើមានករណីបំពាន ឬត្រូវការជំនួយផ្នែកច្បាប់ សូមទំនាក់ទំនងតាមលេខទូរសព្ទបន្ទាន់ ០៦០ ៥០ ៥០ ៥០។**